# អនុក្រឹត្យ

# ស្តីពី

# អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣៦ អនក្រ .បក

# អនុក្រឹត្យ

# ស្តីពី

# អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

*****************

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល សមាស ភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស-រកត ១៩៦-០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

-តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-តាមការយល់ព្រមនៃគណៈរដ្ឋមន្ត្រី

## សំរេច

**មាត្រា ១.-**

ត្រូវបានបង្កើតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដូចមានគំរូចែងក្នុងឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ មានសុពលភាព ១០ឆ្នាំ ចាប់ពីថ្ងៃចេញអត្តសញ្ញាណប័ណ្ណនេះ ។

**មាត្រា ៣.-**

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ អាចផ្តល់ជូនបានចំពោះតែ ប្រជាពលរដ្ឋខ្មែរ ទាំងពីរភេទ ដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ។

**មាត្រា ៤.-**

ក្នុងការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ អាជ្ញាធរមានសមត្ថកិច្ច ត្រូវពិនិត្យ :

-សំបុត្រកំណើត ឬ

-សាលក្រមរបស់តុលាការបញ្ជាក់ទទួលស្គាល់ថា ជននោះកើតពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ ឬ

-ព្រះរាជក្រឹត្យប្រកាសទទួលស្គាល់ការសុំទាមទារសញ្ជាតិខ្មែររបស់សាមីជន ឬ

-ព្រះរាជក្រឹត្យប្រកាសទទួលស្គាល់ការសុំចូលសញ្ជាតិខ្មែររបស់សាមីជន ឬ

-ឯកសារ ឬភស្តុតាងបញ្ជាក់ថា សាមីជន កើតនៅកម្ពុជា ពីឪពុក ឬម្តាយ ដែលកើតនៅកម្ពុជា ឬ

-ឯកសារ ឬភស្តុតាងបញ្ជាក់ថា សាមីជនធ្លាប់មានសញ្ជាតិខ្មែរ ឬ

-ឯកសារ ឬភស្តុតាងបញ្ជាក់ថា សាមីជន កើតពីឪពុក ឬម្តាយ មានសញ្ជាតិខ្មែរ ឬ

-ឯកសារណាមួយ ដែលអាចបញ្ជាក់បានថា ជននោះជាប្រជាពលរដ្ឋខ្មែរ ។

ក្នុងការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ មន្ត្រីមានសមត្ថកិច្ច ត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនតាមទោសប្បញ្ញត្តិ នៃច្បាប់ស្តីពីសញ្ជាតិ ក្នុងករណីដែលខ្លួនចេញអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរអោយជនណាម្នាក់ដែលពុំមានសញ្ជាតិខ្មែរ ។

**មាត្រា ៥.-**

បែបបទនៃការសុំអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ក្នុងការទទួលស្គាល់ភស្តុតាងបញ្ជាក់អំពីសញ្ជាតិត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ដោយមានការយល់ព្រមពីរាជរដ្ឋាភិបាល ។

**មាត្រា ៦.-**

មានតែ មន្ត្រីដែលមានមុខតំណែង អភិបាលខេត្ត ក្រុង ជាមន្ត្រីមានសមត្ថកិច្ចក្នុងការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

មន្ត្រីនេះមិនអាចផ្ទេរ ឬប្រគល់សិទ្ធិអំណាចនេះអោយមន្ត្រីម្នាក់ទៀតបានឡើយ ។

**មាត្រា ៧.-**

អ្នកសុំអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ត្រូវបង់អាករ តាមការកំណត់របស់ប្រកាសអន្តរក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៨.-**

ថ្លៃអាករនេះត្រូវបង់ចូលថវិកាជាតិ ។

បែបបទនៃការប្រមូលអាករនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ។

**មាត្រា ៩.-**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០.-**

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីមុខងារសាធារណៈគ្រប់ប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវទទួលអនុវត្ត អនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហត្ថលេខា និង ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦

**នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២**

**ហត្ថលេខា ហត្ថលេខា**

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

បានប្រគ្រំទូលថ្វាយ និងជំរាបជូន

សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយករដ្ឋមន្ត្រីទី២

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា ហត្ថលេខា**

**ស ខេង យូ ហុកគ្រី**

កន្លែងទទួល

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខធិការដ្ឋានរដ្ឋសភា

-អគ្គនាយកដ្ឋានព្រះបរមរាជវាំង

-ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២

-ដូចមាត្រា១០

-ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធនៃអនុក្រឹត្យ ស្តីពីការបង្កើតអត្តសញ្ញាប័ណ្ណ សញ្ជាតិខ្មែរ

## រូបអត្តសញ្ញាប័ណ្ណ